ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victims**

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១

**<u>សេចក្តីរំលឹកព័ត៌មាន</u>**

**អង្គភាពគាំពារជនរងគ្រោះរៀបចំវេទិកាថ្នាក់តំបន់លើកទី៥ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ៣០០ នាក់ នៃសំណុំរឿង ០០២ នៅខេត្តសៀមរាប**

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី៥ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២ ចំនួន ៣០០ នាក់ មកពីខេត្តប៉ៃលិន បន្ទាយមានជ័យ កំពង់ធំ កំពង់ចាម កំពង់ស្ពឺ និងសៀមរាប។ វេទិកាថ្នាក់តំបន់នេះនឹងប្រព្រឹត្តទៅនៅសណ្ឋាគារ **Allson Angkor Paradise Hotel ក្រុងសៀមរាប នៅថ្ងៃព្រហស្បត្តិ៍ ទី១៩ ខែឧសភា ឆ្នាំ២០១១ ចាប់ពីម៉ោង ៧:៣០ នាទីព្រឹក** *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរក្សាការសម្ងាត់)*។

វេទិកាថ្នាក់តំបន់នេះគឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានាដែលអង្គភាពគាំពារជនរងគ្រោះអនុវត្តគម្រោងរបស់ខ្លួនស្តីពីការចូលរួមរបស់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ឆ្នាំ២០១១ ដើម្បីផ្តល់សិទ្ធិអំណាចឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការសំណុំរឿង ០០២។ វេទិកាថ្នាក់តំបន់នេះមានគោលបំណងលើកកម្ពស់ដល់ការចូលរួមរបស់ជនរងគ្រោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី នូវទីកន្លែងមានសុវត្ថិភាព និងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលមកពីបណ្តាខេត្តទាំងនោះដើម្បី៖

- ជួបជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សាអំពីសិទ្ធិក្នុងដំណើរការជម្រះក្តី និងជាពិសេសប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងជាសមូហភាព ដើម្បីរៀបចំគម្រោងទាមទារសំណងទាំងនោះ។
- ជួបជាមួយមន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវត្តថ្មីៗរបស់ អ.វ.ត.ក។ និង

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

- ជួបជាមួយដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធន៍សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២។

វេទិកាដើមបណ្ដឹងរដ្ឋប្បវេណីថ្នាក់តំបន់នានា បានរៀបចំយ៉ាងជោគជ័យ ក្នុងឆ្នាំ២០១១ នេះ រួមមាន៖ នៅខេត្តក្រចេះ កំពត ស្វាយរៀង កំពង់ឆ្នាំង ហើយបច្ចុប្បន្ននេះនៅខេត្តសៀមរាប។ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ អង្គភាពគាំពារជនរងគ្រោះបានរៀបចំវេទិកាថ្នាក់តំបន់ចំនួន ៩ លើក សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២.៦១៥ មកពីខេត្តទាំង ២៤ នៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឌឹម សុវណ្ណារ៉ុម**
អ្នកនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ០៩៤
អ៊ីម៉ែល៖ dim.sovannarom@eccc.gov.kh

**លោក អ៊ឹម សុភា**
មន្ត្រីសម្របសម្រួល VSS/អ.វ.ត.ក
ទូរស័ព្ទ៖ +៨៥៥ (0) ៧៧ ៧៧៧ ៣៦៧
ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ២១៩ ៨១៤ លេខបន្ត ៦៦០២
អ៊ីម៉ែល៖ im.sophea@eccc.gov.kh

**លោក Lars OLSEN**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់ អ.វ.ត.ក
ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ២១៩ ៨១៤ លេខបន្ត ៦១៦៩
អ៊ីម៉ែល៖ olsen@un.org